អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០២៩. សណ.១៧អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៧

# លិខិតអនុញ្ញាត

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយ ព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- អនុវត្តតាមការកំណត់របស់អនុក្រឹត្យ លេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- អាជ្ញាបណ្ណរួមលេខ២២៩.អ ចេញឱ្យលោក យាន កែវ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៨
- យោងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៤៩៨.សរ-១៦-អអក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦
- យោងតាមតម្លៃប្រេងម៉ាស៊ូតលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៧
- យោងតាមចំណារឯកភាពលើកំណត់បង្ហាញរបស់នាយកដ្ឋានបញ្ជីថ្លៃលក់ និងត្រួតពិនិត្យគណនេយ្យសេវាកម្ម លេខ០០៦-១៧-បថល ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

## អនុញ្ញាត

**ប្រការ ១** -

ផ្អែកតាមតារាងថ្លៃលក់អគ្គិសនីនៅក្នុងប្រការ១ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៤៩៨.សរ-១៦-អអក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ និងផ្អែកលើមូលដ្ឋានថ្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារ ជាមធ្យម នៅក្នុងខែមករា ឆ្នាំ២០១៧ មានតម្លៃស្មើនឹង ៧២៤ (ប្រាំពីររយម្ភៃបួន) ដុល្លារអាមេរិកក្នុង១តោន អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចអនុញ្ញាតឱ្យសេវាករ យាន កែវ អ្នកកាន់អាជ្ញាបណ្ណលេខ២២៩.អ ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅទីរួមស្រុកស្វាយលើ ខេត្តសៀមរាប អនុវត្តអត្រាថ្លៃលក់ស្មើនឹង ២,៤០០ (ពីរពាន់បួនរយ) រៀលក្នុង១គីឡូវ៉ាត់ម៉ោង។

**ប្រការ ២** -

អត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យអនុវត្តចំពោះការចេញ "វិក្កយបត្រថ្លៃអគ្គិសនី" ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ រហូតដល់មានការអនុញ្ញាតជាថ្មីដោយអាជ្ញាធរអគ្គិសនីកម្ពុជា

ទៅតាមកម្រិតថ្លៃប្រេងឥន្ធនៈលើទីផ្សារខេត្តសៀមរាប។ អ្នកកាន់អាជ្ញាបណ្ណមិនត្រូវផ្លាស់ប្តូរខួប និងពេលវេលាក្នុងការកត់ត្រាលេខអំណាននាឡិកាស្ទង់ កាលបរិច្ឆេទនៃការចេញវិក្កយបត្រថ្លៃអគ្គិសនី និងការបែងចែកក្រុមអតិថិជនទេ ក្នុងការអនុវត្តអត្រាថ្លៃលក់អគ្គិសនីថ្មីខាងលើ។ បញ្ជីថ្លៃលក់អគ្គិសនីចាស់ដែលបានដាក់ឱ្យប្រើប្រាស់ ត្រូវចាត់ទុកជានិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ។

**ប្រការ ៣** -

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីនេះ មានប្រសិទ្ធភាពអនុវត្តចំពោះអ្នកប្រើប្រាស់អគ្គិសនីដែលឋិតនៅក្នុងតំបន់ចែកចាយរបស់សេវាករ យាន កែវ ប៉ុណ្ណោះ។

**ប្រការ ៤** -

សេវាករ យាន កែវ មានភារកិច្ចផ្សព្វផ្សាយអំពីការអនុញ្ញាតនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ឆី និរិន្ទ**

ចម្លងជូនៈ

- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តសៀមរាប
- មន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប
- សាលាស្រុកស្វាយលើ
- សាលាឃុំស្វាយលើ

"ដើម្បីជូនជ្រាប"

- សេវាករ យាន កែវ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ